ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ០០០២ ព.ណ.អ.ជ.ស

ថ្ងៃ ចន្ទ ៦ រោច ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២១

# សេចក្តីជូនដំណឹង

## ស្តីពី

## ថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ

- យោងប្រកាសអន្តរក្រសួងលេខ១៧២ពណ. អវព.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ

ផ្អែកតាមតម្លៃមធ្យមប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ ថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី០១ ដល់ ១៥ ខែមករា ឆ្នាំ២០២១ នឹងត្រូវលក់ ៣.៣៦០រៀល/១លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.១១០រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត។

ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន និងដោយមានការរួមចំណែកពីក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈនៅកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ចំនួន៤សេនដុល្លារ/លីត្រ ។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈសម្រាប់អនុវត្ត **ចាប់ពីថ្ងៃទី០១ ដល់ ១៥ ខែមករា ឆ្នាំ២០២១** នឹងចុះមក ៣.២០០ រៀល/លីត្រ សម្រាប់សាំងធម្មតា EA92 និង ២.៩៥០ រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត ។

ការគណនាថ្លៃលក់រាយប្រេងឥន្ធនៈមានលម្អិតដូចតារាងខាងក្រោម៖

**តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា**

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ (Gasoline 92) | | ប្រេងម៉ាស៊ូត/លីត្រ (Gasoil) | |
|---|---|---|---|---|---|
| ១ | Average MOPS | | ០,៣៣៨៧ ដុល្លារ | | ០,៣៥៦៧ ដុល្លារ |
| ២ | ពន្ធ៖ | | ០,១៨៤៧ ដុល្លារ | | ០,០៧៤២ ដុល្លារ |
| | ពន្ធគយ | ០,០៦៣៥ ដុល្លារ | | ០,០០០០ ដុល្លារ | |
| | អាករបន្ថែម | ០,០២០០ ដុល្លារ | | ០,០៤០០ ដុល្លារ | |
| | អាករពិសេស | ០,១០១៣ ដុល្លារ | | ០,០៣៤២ ដុល្លារ | |
| ៣ | PREMIUM | | ០,២០ ដុល្លារ | | ០,២៣ ដុល្លារ |
| ៤ | អាករលើតម្លៃបន្ថែម (១០% នៃ ១+២+៣) | | ០,០៧២៣ ដុល្លារ | | ០,០៦៦១ ដុល្លារ |
| ៥ | ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ) | | ០,៧៩៥៨ ដុល្លារ | | ០,៧២៧០ ដុល្លារ |
| ៦ | ថ្លៃលក់រាយ/លីត្រ (គិតជារៀល) | | ៣.២១៩ រៀល | | ២.៩៤១ រៀល |
| ៧ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ) | | ០,៨០ ដុល្លារ | | ០,៧៣ ដុល្លារ |
| ៨ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល) | | ៣.២០០ រៀល | | ២.៩៥០ រៀល |

សម្គាល់៖ អត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដែលស្មើនឹង៤.០៤៥រៀល/ដុល្លារអាមេរិក

## តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង<br>EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង<br>Gasoil (USD/Barrel) |
|---|---|---|
| ១៦ ធ្នូ ២០២០ | ៥២,៥៥ | ៥៦,២៨ |
| ១៧ ធ្នូ ២០២០ | ៥៤,២០ | ៥៧,៣២ |
| ១៨ ធ្នូ ២០២០ | ៥៤,៦០ | ៥៧,១៩ |
| ២១ ធ្នូ ២០២០ | ៥៣,១៥ | ៥៦,២០ |
| ២២ ធ្នូ ២០២០ | ៥២,៦៩ | ៥៥,៥៦ |
| ២៣ ធ្នូ ២០២០ | ៥២,៨២ | ៥៥,៦៨ |
| ២៤ ធ្នូ ២០២០ | ៥៤,៧៤ | ៥៧,៥១ |
| ២៨ ធ្នូ ២០២០ | ៥៤,០៣ | ៥៧,២៦ |
| ២៩ ធ្នូ ២០២០ | ៥៣,៩៦ | ៥៧,០៨ |
| ៣០ ធ្នូ ២០២០ | ៥៤,៥១ | ៥៦,៩១ |
| ៣១ ធ្នូ ២០២០ | ៥៥,១៨ | ៥៦,៨៩ |
| មធ្យមភាគ ១១ថ្ងៃ | ៥៣,៨៥៧៣ | ៥៦,៧១៦៤ |
| មធ្យមភាគ (ដុល្លារ/លីត្រ) | ០,៣៣៨៧ | ០,៣៥៦៧ |

**ក្រាហ្វិកបម្រែបម្រួលថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ដល់ ០១ ខែមករា ឆ្នាំ២០២១**




សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិតាមការចាំបាច់ ។

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម